**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៧៨៣៨ សហវ.វស

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ាម្ចាស់**

**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាល**

**កម្មវត្ថុ** : ករណីការរួមចំណែករបស់រាជរដ្ឋាភិបាល ទៅនឹងគំរោងដែលហិរញ្ញប្បទានផ្ទាល់ដោយបណ្ដាប្រទេស និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិជាដៃគូអភិវឌ្ឍន៍ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ទូលបង្គំ ខ្ញុំសូមទូលថ្វាយ និងជំរាបជូនឯកឧត្តម លោកជំទាវអ្នកអង្គម្ចាស់មេត្តាជ្រាប និងទ្រង់ជ្រាបថា កន្លងមកមានក្រសួង-ស្ថាប័នមួយចំនួនបានចុះកិច្ចព្រមព្រៀងអនុវត្តគំរោងជាមួយដៃគូអភិវឌ្ឍន៍ ដែលមានភ្ជាប់ដោយល័ក្ខខ័ណ្ឌពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចជាកាតព្វកិច្ចបង់ពន្ធ អាករ និងការរួមចំណែកថវិកាបដិភាគ ជាដើម ដោយមិនមានការពិគ្រោះយោបល់ និងមានការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឡើយ ។ បញ្ហានេះបង្កអោយមានផលវិបាកមួយចំនួនដូចជា ៖

-ការអនុវត្តន៍នីតិវិធីហិរញ្ញវត្ថុមិនបានត្រឹមត្រូវ ដោយសារពេលវេលាប្រចុចញ៉ុច

-បង្កអោយមានការយឺតយ៉ាវក្នុងការអនុវត្តន៍គំរោង ដោយសារមិនបានដឹងនិងត្រៀមលក្ខណៈជាមុន

-បង្កសម្ពាធមិនបានគ្រោងទុកដល់តុល្យការថវិកាបដិភាគ

-ប៉ះពាល់ដល់សង្គតភាពនៅក្នុងការអនុវត្តន៍គោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ រវាងគំរោង និងរវាងក្រសួង-ស្ថាប័ន ។

ដើម្បីធានាអោយការអនុវត្តន៍គំរោងប្រព្រឹត្តទៅដោយរលូន ស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្នើសុំអោយក្រសួង-ស្ថាប័ននានា មុនពេលចុះកិច្ចព្រមព្រៀងឬមុនពេលមានការឯកភាពតាមរូបភាពណាមួយជាដៃគូអភិវឌ្ឍន៍ ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចជាការអនុញ្ញាតអោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋ ការចូលរួមថវិកាបដិភាគជាសាច់ប្រាក់ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន ។

ក្នុងករណីមិនមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនទេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងមិនទទួលខុសត្រូវចំពោះការរាំងស្ទះដល់ការអនុវត្តន៍គំរោងទេ ។ ក្នុងករណីនេះ ប្រសិនបើពិនិត្យឃើញថាមានភាព

ចាំបាច់ នឹងតម្រូវអោយប្រើប្រាស់ និងអនុវត្តនីតិវិធីជាធរមានក្នុងក្របខ័ណ្ឌនៃឥណទាន ថវិកាចរន្តនៃស្ថាប័ននោះផ្ទាល់តែម្តង ។

អាស្រ័យហេតុដូចបានជំរាបជូន និងទូលថ្វាយខាងលើ សូមឯកឧត្តម លោកជំទាវ អ្នកអង្គម្ចាស់មេត្តាជ្រាប ហើយសូមផ្តល់កិច្ចសហប្រតិបត្តិការប្រកបដោយសុវត្ថិភាពខ្ពស់ ។

សូមឯកឧត្តម លោកជំទាវ អ្នកអង្គម្ចាស់មេត្តាទទួល និងទ្រង់ទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ និង ពីទូលបង្គំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន** :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ